01352827

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
23 / 11 / 2016
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ ទី ២៣ ខែ សីហា ឆ្នាំ ២០១៦

## សវនាការលើកស្តុតាង - ថ្ងៃ ៤៤៣

រៀបចំដោយ៖ កញ្ញា ជា ស៊ីវហ៊ាង និង កញ្ញា Stavroula PAPADOPOULOS

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម យ៉ា សុខន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ, ចៅក្រម ធូ មណី |
| ចៅក្រមបំរុង៖ ចៅក្រម Martin Karopkin |
| ក្រឡាបញ្ជី ៖ កញ្ញា ជា ស៊ីវហ៊ាង, និង កញ្ញា Stavroula PAPADOPOULOS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Dale LYSAK, លោក សេង លាង, លោក Nicholas KOUMJIAN, |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក លីវ សុវណ្ណ, លោកស្រី Doreen CHEN |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ហុង |

| |
|---|
| គីមស្វួន, លោកស្រី ស៊ីន សុវន, លោក វ៉េន ពៅ, លោក ឡោ ជុនធី |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ អ៊ុំ យឿន (2-TCCP-274), ស៊ូ សុធារី (2-TCCP-224) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី សួ សុធារី, លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោក មៀច សុវណ្ណា, លោក ឡាយ ណារ៉ា, លោក នូ មនោរត្ន័, លោកស្រី យស សិរីរ័ត្ន, កញ្ញា សេង សុធារស្មី, កញ្ញា Elodie KANCEL |

| <u>ពេលវេលាទូទៅរបស់តុលាការ៖</u> | | |
|---|---|---|
| ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០១ | បញ្ចប់ម៉ោង៖ ១៦.០១ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.០១ | បញ្ចប់ម៉ោង៖ ១០.២៦ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣២ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៤.៥៩ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ១៨ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០១ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៣ | ០៩.០៥ |
| ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿង (2-TCCP-274) | សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា<br><br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.០៥<br>០៩.៣៩<br>១០.៣១<br>១៣.៣០<br>១៤.០០ | ០៩.៣៨<br>១០.០១<br>១១.៣២<br>១៣.៥៩<br>១៤.១៨ |
| សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្ដី នួន ជា សុំឱ្យទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមទៅតាមវិធាន | អង្គជំនុំជម្រះ | ១០.២៧ | ១០.៣១ |

| | | | |
|---|---|---|---|
| ៨៧(៤) (វិធានផ្ទៃក្នុង) | | | |
| ការកត់សម្គាល់ដោយលោកស្រីចៅក្រម Claudia FENZ | អង្គជំនុំជម្រះ | ១៣.៣៦ | ១៣.៣៦ |
| ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី (2-TCCP-224) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា | ១៤.២៣<br>១៤.២៧<br>១៥.៣៧ | ១៤.២៧<br>១៥.៣៧<br>១៦.០០ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ចៅក្រម យ៉ា សុខន ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគី ទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន (2-TCCP-274)</u>**

សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា មេធាវីការពារក្ដី នួន ជា និងមេធាវីការពារក្ដី ខៀវ សំផន តាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-274។

**<u>សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើររបស់មេធាវីការពារក្ដី នួន ជា សុំឱ្យទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមទៅតាមវិធាន ៨៧(៤) (វិធានផ្ទៃក្នុង)</u>**

អង្គជំនុំជម្រះ សម្រេចទៅលើសំណើរបស់មេធាវីការពារក្ដី នួន ជា អនុលោមតាមវិធាន ៨៧(៣) និង (៤) សុំឱ្យទទួលយកឯកសារចំនួន ៤ ជាឯកសារភ័ស្តុតាង។ ឯកសារពីរ ក្នុងចំណោមនោះ គឺជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ដើមបណ្ដឹង 2-TCCP-274 (ឯកសារ E319/45.4.11) ហើយឯកសារពីរទៀតគឺជាសម្រង់នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ដើមបណ្ដឹង 2-TCCP-224 (ឯកសារ E319/45.4.8)។ អង្គជំនុំជម្រះបានរម្លឹងពីការអនុវត្តរបស់ខ្លួនក្នុងការទទួលយកជាភ័ស្តុតាងនូវចម្លើយ

ពីមុនៗរបស់សាក្សី ឬ ដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងមកផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានអនុញ្ញាតិតាមសំណើរបស់មេធាវីការពារក្ដី នួន ជា ដែលបានស្នើសុំឱ្យទទួលយកជាភ័ស្ដុតាងនូវសម្រង់នៅក្នុងឯកសារ E319/45/4.11 និងដាក់លេខឯកសារ E3/6011B។ អង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចលើផ្នែកសេសសល់នៃសំណើនេះក្នុងពេលសមស្របខាងមុខ។

__ការអន្ដរាគមន៍របស់សហមេធាវីនាំមុខទៅលើការតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណី__

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើអន្ដរាគមន៍ទៅលើការតាំងសំណួររបស់មេធាវីការពារក្ដី នួន ជា ទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-274 ដោយថាសំណួរគឺមានលក្ខណៈច្រំដែលជាពិសេសគឺ កាលបរិច្ឆេទនៃការដែលគាត់បានរួមភេទលើកដំបូងជាមួយស្វាមីរបស់គាត់។ អង្គជំនុំជម្រះអនុញ្ញាតិឱ្យមេធាវីការពារក្ដីបន្តតាំងសំណួរ។

__ការកត់សម្គាល់ដោយលោកស្រីចៅក្រម Claudia FENZ__

ក្នុងអំឡុងពេលនៃការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-274 ចៅក្រម FENZ បានធ្វើការកត់សម្គាល់ទៅលើការតាំងសំណួរដោយមេធាវីការពារក្ដី នួន ជា ទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី។ ចៅក្រម FENZ បានលើកឡើងថាសំណួររបស់មេធាវីការពារក្ដីមានភាពច្រំដែលដែលផ្ទុយពីវិធាន។ ចៅក្រម FENZ ក៏បានរម្លឹកផងដែរដល់មេធាវីការពារក្ដី នួន ជា ថាទោះបីជាមានភាពចាំបាច់ក្នុងការសួរដេញដោលស៊ីជម្រៅ ប៉ុន្ដែត្រូវគិតអំពីបញ្ហារសើប ឬសម្ងាត់ផងដែរ។

__ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី សួរ សុធារី (2-TCCP-224)__

ប្រធានអង្គជំនុំជម្រះ សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា តាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី សួ សុធារី (2-TCCP-224)។

## New

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/6011 B | E319/45.4.11 | 01027323-01027325; 01143513-01143514; - | Excerpt of Civil Party application of 2-TCCP-274 13-VSS-00318 | C | - | - | - |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/6011 A | E307/6.1.5 | 01003354-01003356; 01137889-01137890; 01030292-01030293 | Authority 5: Supplementary Information of Civil Party 2-TCCP-274 (09-VU-01594) | C | 01003354; 01003355; 01003356; | 01137889; 01137890; | 01030292; 01030293; |
| E3/6011 | D22/511 | 00496717-00496725; - - | Civil Party application 2-TCCP-274 09-VU-01594 | C | 00496720 - 00496721 | - | - |
| E3/1060 4 | E393.2 | - 01222328-01222936; - | Annex 2: OCIJ S-21 Prisoners List 31 March 2016 | P | - | 01222672 | - |
| E3/765 | D248/4.10 | 00376472-00376507; 00539976-00540007; 00540008-00540037 | Revolutionary Youth Number 10 October 1978 | P | 00376494 | 00539994 | 00540024 - 00540025 |
| E3/4607 | D22/31 | 00279722-00279738; 00279708-00279721; 00845977-00845998 | Civil Party Application of Ms. SOU Sotheavy | P | 00279728 | 00279712 | 00845987 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

(០៩.០៥)

- សម្រេចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាឯកសារភ័ស្តុតាង តាមសំណើរបស់មេធាវីការពារក្តី នួន ដោយអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ (១០.២៧)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃ ពុធ ទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ។ (១៥.៥៩)

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

កញ្ញា ជា ស៊ីមហ៊ុន Stavroula PAPADOPOULOS